## ធ្វើការរួមគ្នាសំរាប់លទ្ធផល

### នេះគឺជាឧទាហរណ៍ខ្លះៗនៃអ្វីដែលយើងបានបំពេញក្នុងរយៈពេលពីរឆ្នាំ

- យើងបានស្តាបនាក្រុមប្រឹក្សាឡើងវិញពីបាតដៃទទេ;
- យើងបានចងក្រង និងអនុវត្តការស្ទង់មតិអំពីការផ្គាប់ចិត្តអតិថិជនចំនួនពីរច្បាប់ ដែលត្រូវបានផ្ញើចេញទៅជូនអតិថិជន DVR ចំនួន 1,600 នាក់;
- យើងបានប្រើប្រាស់ព័ត៌មាន ដែលបានផ្តល់ជូនដោយអតិថិជន ទុកជាមូលដ្ឋានសំរាប់អនុសាសន៍ក្នុងការបង្កើតគោលនយោបាយ ដែលបានធ្លាក់ដល់ដៃបណ្តាអ្នកដឹកនាំជាន់ខ្ពស់របស់ DVR ក្នុងខណៈដែលពួកគេកំពុងធ្វើការសម្រេចលើវិធានការបង្កើនគុណភាពសេវាកម្ម;
- យើងបានផ្តល់ការឧបត្ថម្ភដល់វេទិកាអតិថិជនចំនួន 8 លើកពេញលើផ្ទៃរដ្ឋ ហើយបានទទួលការជួយផ្តល់មតិពីអ្នករស់នៅក្នុងរដ្ឋវ៉ាស៊ីនតោនជាង 200 នាក់ .

### យើងបានស្តាបនាដៃគូដ៏មានប្រសិទ្ធិភាពជាច្រើន ដែលបានហុចលិទ្ធផលក្នុង ៖

- ការទាក់ទងគ្នាជាញឹកញាប់រវាង DVR និងអតិថិជនរបស់វា;
- កាលានុវត្តភាពដ៏មានអត្ថរសសំរាប់ភាពដឹកនាំដោយបណ្តាមនុស្សដែលមានពិការភាព ដែលមានសក្តានុពលលើគោលនយោបាន និងការនុវត្តន៍;
- ការបង្កើនលទ្ធភាពក្នុងការចេញចូលប្រើប្រាស់ការិយាល័យនានារបស់ DVR;
- ការមានពេលវេលាច្រើនសំរាប់ឲ្យបណ្តាអតិថិជនស្នើសុំសវនាការយុត្តិធម៌ផ្សេងៗ

## ការក្លាយជាសមាជិក

អភិបាលរដ្ឋបានចាត់តាំងសមាជិក ឲ្យស្ម័គ្រចិត្តជួយបម្រើការងារសំរាប់អាណត្តិបីឆ្នាំ ។ បណ្តាសមាជិករបស់យើងតំណាងឲ្យក្រុមពាក់ព័ន្ធនានាសរុបមានដូចជា ៖ អតិថិជនបច្ចុប្បន្ន និងអតីតរបស់ DVR, ពាណិជ្ជកម្ម និងឧស្សាហកម្ម, ការងារ, DVR (ទាំងចេញពីមូលដ្ឋាន និងទាំងដោយនាយកដឹកនាំ), ដៃគូ VR នៃក្រុមកុលសម្ពន្ធ, កម្មវិធីស្តារនីតិសម្បទាសហគមន៍, កម្មវិធីជំនួយអតិថិជន, ការិយាល័យស្នងការអប់រំសាធារណៈ, ហើយនិងកម្មវិធីហ្វឹកហ្វឺន និងអប់រំមាតាបិតា ។ យើងសូមស្វាគមន៍ដល់ការដាក់ពាក្យសុំរបស់អ្នកដឹកនាំទាំងអស់ គឺទាំងថ្មោងថ្មី និងទាំងមានបទពិសោធន៍ស្រាប់ ។ ដើម្បីស្នើសុំឲ្យមានការបន្ធូរបន្ថយដោយសមរម្យនៅក្នុងកំឡុងពេលនៃដំណើរការដាក់ពាក្យសុំ, សូមទាក់ទងនាយកដឹកនាំរបស់យើងដោយប្រើព័ត៌មានខាងក្រោមនេះ ។

### ជំហានជាបន្តបន្ទាប់ រួមមាន ៖

- ការបំពេញលិខិតដាក់ពាក្យសុំរបស់អភិបាលរដ្ឋសំរាប់បណ្តាស្នងការផ្នែកប្រតិបត្តិ (មានបម្រុងជូននៅលើទំព័រវិបសៃត៍របស់យើង);
- ការបញ្ជូនសំបុត្រចាប់អារម្មណ៍ទៅជូនអភិបាលរដ្ឋ ដើម្បីបញ្ជាក់អំពីជំនាញការនានារបស់អ្នក ហើយនិងមូលហេតុដែលអ្នកចង់ចូលបម្រើការងារនៅក្នុងក្រុមប្រឹក្សា WSRC;
- ការផ្តល់សំបុត្រអនុសាសន៍ពីជនអ្នកធ្វើលិខិតគាំទ្របេក្ខភាពនៃកាដាក់ពាក្យសុំរបស់អ្នក;


**Washington State Rehabilitation Council**
4565 7th Ave. SE
Olympia, WA 98504-5343
www.wastrehabcouncil.org

ទូរស័ព្ទ ៖ 360-725-3690(V)
ទូរស័ព្ទឥតគិតថ្លៃ ៖ 1-866-252-2939
អ៊ីមែល ៖ Brounjm@dshs.wa.gov


Washington State Rehabilitation Council



# ចូរដាក់ពាក្យសុំចូលជាសមាជិកនៅថ្ងៃនេះ

www.wastrehabcouncil.org

> “ កុំឲ្យមានចិត្តសង្ស័យថា ក្រុមដ៏តូចមួយរបស់បណ្តាពលរដ្ឋដែលមានគំនិតម៉ឺងមាត់មិនអាចផ្លាស់ប្តូរពិភពលោកនេះឡើយ ។ តាមការពិត, វាគឺជាសារធាតុតែមួយគត់ ដែលបានធ្វើឲ្យពិភពលោកយើងនេះមានការប្រែប្រួល ។ ”
>
> – Margaret Mead

WSRC
Washington State Rehabilitation Council
*Building Inroads to Employment and Success*


DSHS 22-1188 CA (2/07)

# ចូរចូលរួមជាមួយក្រុមប្រឹក្សាស្តារនីតិសម្បទារដ្ឋវ៉ាស៊ីនតោននៅថ្ងៃនេះ

## អំពីយើង

ក្រុមប្រឹក្សាស្តារនីតិសម្បទារដ្ឋវ៉ាស៊ីនតោន (Washington State Rehabilitation Council – WSRC) គឺជាគណៈនាយកប្រឹក្សាភិបាលមួយដែលមានសមាជិកដប់ប្រាំរូប ។ យើងធ្វើការជាមួយនាយកដ្ឋានស្តារនីតិសម្បទាវិជ្ជាជីវៈ (Division of Vocational Rehabilitation – DVR) ដើម្បីបង្កើនចំនួនបុគ្គលិកធ្វើការ ដែលមានពិការភាពនៅក្នុងក្រុមការងាររបស់រដ្ឋវ៉ាស៊ីនតោន ។

ក្រុមប្រឹក្សាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1994 ដោយការផ្លាស់ប្តូរនានាដែលគេបានធ្វើទៅលើច្បាប់ស្តារនីតិសម្បទា (Rehabilitation Act) នៅថ្នាក់សហព័ន្ធ និងដោយដីកាប្រតិបត្តិលេខ 94-04 (Executive Order 94-04) ដែលបានចេញដោយអភិបាលរដ្ឋនៅថ្នាក់រដ្ឋ ។ ក្រុមប្រឹក្សាស្តារនីតិសម្បទារដ្ឋ (State Rehabilitation Councils) បង្កើតកាលានុវត្តភាពជូនបណ្តាមនុស្ស ដែលមានពិការភាពដើម្បីកែច្នៃសេវាផ្សេងៗ ដែលជួយទ្រទ្រង់ពួកគេក្នុងការចេញទៅប្រកបការងារ ។

## ការប្តេជ្ញាដើម្បីបុព្វហេតុបម្រើអ្នកដទៃ

បើអ្នកស្រឡាញ់ការរៀនសូត្រ, ការស្តាបនា, ការកសាងទំនាក់ទំនង, និងការទំនុកបម្រុងសំរាប់ឲ្យមានការផ្លាស់ប្តូរក្នុងប្រព័ន្ធនានា, ក្រុមប្រឹក្សា WSRC ផ្តល់កាលានុវត្តភាពគួរជាទីមោទនៈសំរាប់ការស្ម័គ្រចិត្តចូលជួយបម្រើសេវាសាធារណៈ ។

បណ្តាពួកសមាជិកចំណាយពេលវេលា និងកម្លាំងកាយចិត្តប្រាជ្ញាយ៉ាងក្រាស់ក្រែលនៅក្នុងកិច្ចការក្រុមប្រឹក្សារបស់ពួកគេ ។ សមាជិកម្នាក់ៗចូលខ្លួនបម្រើក្នុងគណៈកម្មាធិការពីរ ព្រមទាំងចូលរួមយ៉ាងពេញទំហឹងក្នុងការបំពេញការងារក្នុងក្រុមប្រឹក្សា ។ យើងមានបើកអង្គប្រជុំចំនួនបួនដងក្នុងមួយឆ្នាំ ដែលម្តងៗមានរយៈពេលពីរថ្ងៃ នៅតាមសហគមន៍នានាពេញលើផ្ទៃរដ្ឋ ។ ការងារភាគច្រើនត្រូវបានបំពេញឡើងនៅក្នុងចន្លោះនៃអង្គប្រជុំទាំងនេះ ។

បុគ្គលិកក្រុមប្រឹក្សាជាអ្នករៀបចំអង្គប្រជុំ ហើយបណ្តាសមាជិកដែលចូលរួមត្រូវបានគេចេញប្រាក់សំណងលើថ្ងៃនៃការធ្វើដំណើរ និងម្ហូបអាហារទៅតាមក្បួនខ្នាតគមនាការនានារបស់រដ្ឋ ។

## ការចែករំលែកទេពកោសល្យនានារបស់អ្នក

ការបន្តទទួលជោគជ័យរបស់យើងអាស្រ័យលើកម្លាំងស្នូលរបស់សមាជិកដែលមានការប្តេជ្ញាមុតមាំប្រកបដោយគំនិតប្រាជ្ញា, បទពិសោធន៍, និងទេពកោសល្យដ៏ទូលំទូលាយក្នុងការបម្រើការងារក្នុងក្រុមប្រឹក្សា WSRC ។

បើអ្នកមានបំណងចង់ក្លាយជាសមាជិក, យើងសូមលើកទឹកចិត្ត ឲ្យអ្នកសាកល្បងចូលរួមក្នុងអង្គប្រជុំមួយរបស់យើង ។ បើអ្នកចង់ជួបពិភាក្សាជាមួយសមាជិកណាម្នាក់ ដែលរស់នៅជិតខាងអ្នក, នោះយើងរីករាយនឹងជួយរៀបចំឲ្យអ្នកបានជួបសមាជិករូបនោះ ។ យើងក៏សូមស្វាគមន៍គ្រប់ទាំងសំណួរ និងចម្ងល់របស់អ្នក ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការចាប់អារម្មណ៍របស់អ្នកនៅក្នុងការងាររបស់យើងនេះ ។

> “មនុស្សគ្រប់រូបគួរមានសិទ្ធិយល់ដឹងអំពីសក្តានុពលរបស់ផងខ្លួនតាមរយៈការបំរើការងារ ។ ក្រុមប្រឹក្សា WSRC ផ្តល់ជូនបណ្តាជនដែលមានពិការភាព, ដែលកំពុងស្វែងរកទីសង្ឃឹម និងកាលានុវត្តភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច, នូវឱកាសដើម្បីបញ្ចេញសម្លេងរបស់ខ្លួនឲ្យគេឯងបានឮ ។”
>
> – John Harrison
> Olympia

## បេសកកម្ម

ដើម្បីជួយឧបត្ថម្ភដល់គ្រប់ឯកត្តជនមានពិការភាព ឲ្យទទួលបាននូវសេវាស្តារនីតិសម្បទាផ្នែកវិជ្ជាជីវៈដែលប្រកបប្រសិទ្ធភាពទៅតាមលក្ខណៈវប្បធម៌ ដែលទ្រទ្រង់ដល់សតិបញ្ញាក្នុងការយល់ដឹងអំពីអនុភាព និងមោទនភាពខ្លួន ហើយថែមទាំងលើសពីការរំពឹងរបស់ពួកគេនោះទៅទៀត ។

> “ខ្ញុំបម្រើការនៅក្នុងក្រុមប្រឹក្សា WSRC ពីព្រោះនៅក្នុងទីវាល្អមួយ យើងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងជីវិតរបស់មនុស្ស 10,000 នាក់ ។”
>
> – Bill Murray
> Wenatchee


ដើម្បីស្វែងយល់ព័ត៌មានពិស្តារបន្ថែមអំពីការដាក់ពាក្យសុំចូលជាសមាជិក, សូម

ទូរស័ព្ទ ៖ 1-866-252-2939

អ៊ីមែល ៖ Brounjm@dshs.wa.gov

មើលទំព័រវិបសៃត៍ ៖ www.wastrehabcouncil.org


*យើងខ្ញុំរីករាយនឹងផ្តល់ការបន្ធូរបន្ថយដោយសមរម្យទៅតាមសេចក្តីស្នើសុំ ។*